**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាល**

# គោលនយោបាយជាតិ
# ស្តីពី
# ការអភិវឌ្ឍយុវជនកម្ពុជា

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី
ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១

*រៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# រាជរដ្ឋាភិបាល

# គោលនយោបាយជាតិ
# ស្តីពី
# ការអភិវឌ្ឍយុវជនកម្ពុជា

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី
ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១
*រៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា*

# មាតិកា


១- សេចក្តីផ្តើម............................................................ ១
២- ចក្ខុវិស័យ............................................................ ២
៣- គោលបំណង............................................................ ២
៤- គោលដៅ............................................................ ២
៥- យុទ្ធសាស្រ្ត............................................................ ៣
៥.១- អភិវឌ្ឍក្របខ័ណ្ឌច្បាប់និងយន្តការ.......................................... ៣
៥.២- លើកកម្ពស់ការអប់រំ ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាព.................. ៣
៥.៣-បង្កើនការអប់រំ ការថែទាំ និងការផ្តល់សេវាសុខភាព.................................. ៤
៥.៤- បណ្តុះស្មារតីសហគ្រិនភាព និងទីផ្សារការងារ.......................................... ៤
៥.៥- លើកកម្ពស់កិច្ចការពារ សុវត្ថិភាព សន្តិសុខ និងយុត្តិធម៌.............................. ៥
៥.៦- បង្កើនការចូលរួមរបស់យុវជន.......................................... ៦
៥.៧-លើកកម្ពស់ការសម្រាក ការកម្សាន្ត និងកីឡា.......................................... ៦
៥.៨- លើកកម្ពស់សិល្បៈនិងវប្បធម៌.......................................... ៧
៥.៩- លើកកម្ពស់ការយល់ដឹងពីបរិស្ថាន កសិកម្ម ទេសចរណ៍ និងធុរកិច្ច...................... ៧
៥.១០-បង្កើនការងារស្ម័គ្រចិត្ត.......................................... ៧
៥.១១-លើកកម្ពស់សមភាពយេនឌ័រ.......................................... ៨
៥.១២-ទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀននិងស្ការយុវនីតិសម្បទា.............................. ៨
៦- ផែនការសកម្មភាព............................................................ ៩
៦.១-ការបង្កើតយន្តការ.......................................... ៩
៦.២-ការបង្កើតក្របខ័ណ្ឌគតិយុត្ត.......................................... ១០
៦.៣-ការគាំទ្រហិរញ្ញវត្ថុ.......................................... ១០
៦.៤-ការបណ្តុះបណ្តាលធនធានមនុស្ស.......................................... ១០
៦.៥-ដំណើរការអនុវត្តគម្រោង.......................................... ១០
៧- ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ.......................................... ១១
៨- សេចក្តីសន្និដ្ឋាន............................................................ ១១

## ១-សេចក្តីផ្តើម

ព្រះរាជាណាចក្រកម្ពុជាចាត់ទុកយុវជនជាធនធានគន្លឹះនិងមានតម្លៃបំផុតសម្រាប់អភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ បរិស្ថាន និងការរក្សាសន្តិភាព ទាំងបច្ចុប្បន្ន ទាំងអនាគត។

នៅក្នុងបរិបទសង្គម វប្បធម៌ និងនយោបាយរបស់កម្ពុជា "យុវជន" ជាបុរសនិងស្ត្រីដែលមានសញ្ជាតិខ្មែរពីអាយុ១៥ដល់៣០ឆ្នាំ នៅលីវឬរៀបការហើយ។ យោងតាមជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ២០០៨ យុវជនមាន៣៣ភាគរយនៃចំនួនប្រជារាស្ត្រសរុប។

រាជរដ្ឋាភិបាលបានកំណត់ថា ការអប់រំគឺជាមូលដ្ឋានគ្រឹះដ៏រឹងមាំក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងធានាឲ្យបាននូវកំណើនសេដ្ឋកិច្ចមួយប្រកបដោយចីរភាព ឆ្ពោះទៅរកការកាត់បន្ថយភាពក្រីក្រ។ ក្នុងឆ្នាំសិក្សា២០១០-២០១១ អត្រាពិតនៃការសិក្សានៅបឋមសិក្សាមាន ៩៦,១ភាគរយ មធ្យមសិក្សាបឋមភូមិមាន៣៣,៩ភាគរយ មធ្យមសិក្សាទុតិយភូមិមាន២០,៨ភាគរយ ចំនួនអក្ខរជនសរុប(អាយុ១៥-២៤ឆ្នាំ)មាន៨៧,៥ភាគរយ(ជំរឿនទូទៅនូវប្រជារាស្ត្រឆ្នាំ២០០៨) និងនិស្សិតនៅឧត្តមសិក្សាមាន ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ថ្នាក់បរិញ្ញាបត្ររង ថ្នាក់បរិញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិតមាន២៦៣ ០០០នាក់(យោងតាមរបាយការណ៍បូកសរុបឆ្នាំសិក្សា២០០៩-២០១០ របស់ក្រសួងអប់រំ យុវជន និងកីឡា)។

រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់លើយុវជនដែលជាសសរទ្រូងប្រទេសជាតិដោយផ្តល់ការសិក្សាប្រកបដោយគុណភាព និងមានសមត្ថភាពអាចឈានចូលទៅក្នុងទីផ្សារការងារដោយងាយស្រួល។ ក្នុងនោះ ក៏នៅមានយុវជនមួយចំនួនពុំទាន់មានឱកាសទទួលបានការងារសមស្របនៅឡើយ។ រីឯយុវជនដែលមានចំណេះដឹងតិចតួច បានទទួលកម្រៃទាប ក្នុងនោះ ស្ត្រីមិនសូវទទួលបានការងារធ្វើដោយកម្រៃខ្ពស់នៅឡើយ។ យុវជនមួយចំនួនទៀតបានធ្វើចំណាកស្រុកទៅកាន់ទីក្រុង ទីប្រជុំជននានា និងក្រៅប្រទេសដើម្បីស្វែងរកឱកាសក្នុងការរកប្រាក់ចំណូល។ លើសពីនេះពួកគេបានប្រឈមនឹងការលំបាកឬធ្លាក់ចូលក្នុងស្ថានភាពងាយរងគ្រោះ ដែលរួមមានការបោះបង់ការសិក្សា ការបាត់បង់ជម្រើសរបស់ខ្លួន ការសេពគ្រឿងញៀន ការសេពគ្រឿងស្រវឹង និងគ្រោះថ្នាក់នៅតាមកន្លែងធ្វើការ។ល។

ដើម្បីលើកកម្ពស់សិទ្ធិនិងការទទួលខុសត្រូវរបស់យុវជនដែលជាកម្លាំងសកម្មរបស់ប្រទេសជាតិ ព្រមទាំងទប់ស្កាត់និងកាត់បន្ថយនូវភាពអសកម្មខាងលើ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជន សំដៅផ្តល់ឱកាសឲ្យយុវជនគ្រប់រូបអភិវឌ្ឍសមត្ថភាពប្រកបដោយឆន្ទៈ សេចក្តីព្យាយាមនិងមនសិការវិជ្ជាជីវៈ។

គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា រៀបចំឡើងអនុលោមតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីការអប់រំ ច្បាប់ស្តីពីការងារ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងឯកសារអន្តរជាតិពាក់ព័ន្ធនានា ដើម្បីអភិវឌ្ឍយុវជនស្របតាមបរិបទកម្ពុជា។

## ២-ចក្ខុវិស័យ

ដើម្បីធ្វើឲ្យព្រះរាជាណាចក្រកម្ពុជាមានធនធានមនុស្សសម្រាប់ការអភិវឌ្ឍប្រទេសជាតិ រាជរដ្ឋាភិបាលមានចក្ខុវិស័យរយៈពេលវែងដោយប្រមូលផ្តុំកម្លាំងគ្រប់មជ្ឈដ្ឋានក្នុងសង្គមជាតិ សំដៅរួមចំណែកអភិវឌ្ឍយុវជនឲ្យកាន់តែមានលក្ខណសម្បត្តិវិជ្ជមាន និងផ្តល់ឱកាសឲ្យពួកគេអភិវឌ្ឍសក្តានុពលនៅក្នុងការអប់រំ ការងារ សុខភាព ការចូលរួមធ្វើសេចក្តីសម្រេចចិត្ត និងការចូលរួមចំណែកអភិវឌ្ឍគ្រួសារ សហគមន៍ ប្រទេសជាតិ និងពិភពលោក។

## ៣-គោលបំណង

អភិវឌ្ឍយុវជនឲ្យមានបុគ្គលិកលក្ខណៈពេញលេញលើផ្នែករាងកាយ បញ្ញា ស្មារតី សីលធម៌ តម្លៃ និងបំណិន ដើម្បីឲ្យយុវជនក្លាយជាពលរដ្ឋល្អក្នុងសង្គមជាតិ។

## ៤-គោលដៅ

៤.១. ផ្តល់ឱកាសឲ្យយុវជនទទួលបានការអប់រំនិងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈប្រកបដោយគុណភាពនិងសមធម៌។

៤.២. លើកទឹកចិត្តយុវជនឲ្យមានគំនិតផ្តួចផ្តើម គំនិតច្នៃប្រឌិត គំនិតបង្កើតថ្មី និងស្មារតីសហគ្រិនភាព។

៤.៣. លើកកម្ពស់យេនឌ័រប្រកបដោយសមធម៌និងសមភាពដល់យុវជនទាំងពីរភេទ ពិសេសផ្តល់ឱកាសនិងសិទ្ធិអំណាចដល់ស្ត្រី។

៤.៤. អភិវឌ្ឍយុវជនឲ្យមានកាយសម្បទា ចំណេះដឹង ចំណេះធ្វើ សីលធម៌រស់នៅល្អ ចេះរួមរស់ជាមួយគ្នាដោយសន្តិភាពនិងសុខដុម ព្រមទាំងមានស្មារតីស្នេហាជាតិ ស្នេហាប្រជាជន ប្រកបដោយជំនឿជាក់លើខ្លួនឯង សេចក្តីថ្លៃថ្នូរ ភាពជាអ្នកដឹកនាំ និងលើកកម្ពស់ការយល់ដឹងទូលំទូលាយអំពីសង្គម។

៤.៥. បង្កឱកាសឲ្យយុវជនបានចូលរួមបញ្ចេញមតិ ទស្សនៈ និងធ្វើសេចក្តីសម្រេចចិត្តនានាក្នុងការអភិវឌ្ឍសហគមន៍និងសង្គមជាតិ។

៤.៦. ប្រមូលផ្តុំកម្លាំងគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល សហគមន៍ មាតាបិតាឬអ្នកអាណាព្យាបាល ដើម្បីអភិវឌ្ឍយុវជនកម្ពុជា។

## ៥-យុទ្ធសាស្ត្រ

ដើម្បីសម្រេចគោលបំណងនិងគោលដៅខាងលើ យុទ្ធសាស្ត្រសំខាន់ៗមានដូចខាងក្រោម៖

### *៥.១- អភិវឌ្ឍក្របខ័ណ្ឌច្បាប់និងយន្តការ*

- រៀបចំលិខិតបទដ្ឋាននិងយន្តការនានា ដើម្បីគាំទ្រនិងអនុវត្តគោលនយោបាយឲ្យមានប្រសិទ្ធភាព ដោយកំណត់ឲ្យមានកិច្ចសហការនិងភារកិច្ចរបស់ភាគីពាក់ព័ន្ធសំខាន់ៗ
- ធ្វើឲ្យប្រសើរឡើងនិងពន្លឿនការអនុវត្តគោលនយោបាយជាតិ ក្របខ័ណ្ឌច្បាប់យន្តការពាក់ព័ន្ធនានាដែលមានស្រាប់និងយន្តការថ្មីៗ
- កសាងផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជានិងកម្មវិធីនានា ដោយមានសកម្មភាពជាក់លាក់ ពេលវេលា ធនធាន និងក្រសួង ស្ថាប័នទទួលខុសត្រូវ។

### *៥.២ - លើកកម្ពស់ការអប់រំ ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាព*

- ជំរុញនិងលើកទឹកចិត្តយុវជនឲ្យទទួលបាននូវការអប់រំនិងការបណ្តុះបណ្តាលវិជ្ជាជីវៈសមស្រប ជាពិសេស យុវជនដែលពុំសូវមានឱកាសនិងយុវជនដែលងាយរងគ្រោះ ក្នុងនោះយុវជនពិការ
- ជំរុញកម្មវិធីបំណិនជីវិតដែលឆ្លើយតបទៅនឹងតម្រូវការជីវភាពរស់នៅរបស់យុវជននិងទីផ្សារពលកម្ម
- ចូលរួមលើកកម្ពស់គុណភាពអប់រំបច្ចេកវិទ្យា វិទ្យាសាស្ត្រ និងភាសាបរទេសនៅគ្រប់ភូមិសិក្សានៃប្រព័ន្ធអប់រំកម្ពុជាឲ្យស្របតាមតម្រូវការរបស់សង្គមជាតិ និងស្របតាមស្តង់ដាតំបន់និងអន្តរជាតិ
- បង្កឱកាសដល់យុវជនកម្ពុជាទាំងអស់ឲ្យទទួលបាននិងបញ្ចប់ការសិក្សាយ៉ាងហោចណាស់ត្រឹមការអប់រំកម្រិតមូលដ្ឋាន និងបង្កើនអត្រាគង់វង្សនៅគ្រប់ភូមិសិក្សានៃប្រព័ន្ធអប់រំ
- អភិវឌ្ឍមជ្ឈមណ្ឌលយុវជននិងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និងជំរុញលើកទឹកចិត្តយុវជនឲ្យចូលរួមយ៉ាងសកម្មក្នុងការសិក្សានិងការបណ្តុះបណ្តាលវិជ្ជាជីវៈនៅតាមសហគមន៍របស់ខ្លួន

- ជំរុញគ្រឹះស្ថានសិក្សានិងបណ្តុះបណ្តាលវិជ្ជាជីវៈ សហគ្រាសសាធារណៈនិងឯកជន និងអាជ្ញាធរពាក់ព័ន្ធ ចូលរួមលើកទឹកចិត្ត និងផ្តល់ឱកាសឲ្យយុវជនចូលរួមក្នុងសកម្មភាពផ្សេងៗ
- ជំរុញការបណ្តុះបណ្តាលសហគ្រិនភាពដល់យុវជនដោយផ្សារភ្ជាប់ទៅនឹងឱកាសធ្វើជំនួញខ្នាតតូច មធ្យម និងធំ ឲ្យយុវជនចាប់ផ្តើមនិងពង្រីកមុខជំនួញ។

*៥.៣ - បង្កើនការអប់រំ ការថែទាំ និងការផ្តល់សេវាសុខភាព*

- អភិវឌ្ឍនិងពង្រីកការអប់រំសុខភាព និងបង្កើនលទ្ធភាពទទួលបានព័ត៌មានអំពីការអប់រំ និងការបង្ការបញ្ហាមួយចំនួនដូចជា ផ្នែកសុខភាព សុខភាពបន្តពូជ គ្រោះថ្នាក់ចរាចរណ៍ និងគ្រោះថ្នាក់នៅកន្លែងធ្វើការ បញ្ហាអនាម័យនិងការប្រើប្រាស់ទឹកស្អាត សុខភាពផ្លូវចិត្ត ការធ្វើអត្តឃាត និងការទប់ស្កាត់រាល់អំពើហិង្សា
- បង្កើតយន្តការដោយមានយុវជនចូលរួមក្នុងសកម្មភាពអប់រំសុខភាព និងកម្មវិធីចុះដល់សហគមន៍ ដែលជាប្រយោជន៍ដល់យុវជន
- បង្កើនការទទួលសេវាសុខភាពដល់យុវជនប្រកបដោយភាពងាយស្រួល និងមានគុណភាព រួមទាំងសេវាសុខភាពផ្លូវកាយ ផ្លូវចិត្ត សេវាសង្គម ចំពោះយុវជនដែលជាអ្នករងគ្រោះពីអំពើហិង្សា ការជួញដូរ និងការកេងប្រវញ្ចផ្លូវភេទ
- ពង្រឹងបណ្តាញសុវត្ថិភាពផ្នែកសង្គម ធានាឲ្យយុវជនដែលក្រីក្របំផុតទទួលបានសេវាសុខភាព និងបន្តផ្តល់អាទិភាពលើអន្តរាគមន៍ផ្នែកការបង្ការ ការព្យាបាល និងការថែទាំចំពោះក្រុមយុវជនមុខសញ្ញាដែលងាយរងគ្រោះ
- អប់រំ គាំពារ និងថែរក្សាសុខភាពយុវតីមានគភ៌មុនវ័យរៀបការប្រកបដោយគុណភាពពីសំណាក់អ្នកផ្តល់សេវាសុខភាពដែលមានការបណ្តុះបណ្តាលត្រឹមត្រូវ ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធនិងសហគមន៍
- បង្កើនទំនាក់ទំនងជាមួយនឹងមាតាបិតាឬអ្នកអាណាព្យាបាល និងអ្នកប្រឹក្សាពីការផ្តល់សេវាសុខភាព ឥរិយាបថ និងការប្រព្រឹត្តខាងផ្លូវភេទ។

*៥.៤ -បណ្តុះស្មារតីសហគ្រិនភាពនិងទីផ្សារការងារ*

- ជំរុញកិច្ចសហការរវាងក្រសួង ស្ថាប័នសាធារណៈនិងផ្នែកឯកជននានា ដោយធ្វើឲ្យប្រសើរឡើងនូវបរិយាកាសទីផ្សារការងារនិងសហគ្រិនភាពសម្រាប់យុវជន ពិសេសយុវជនដែលបានកំណត់នៅក្នុងក្រុមគោលដៅអាទិភាព និងពង្រឹងភាពជាដៃគូជាមួយយុវជនក្នុងការអប់រំ បណ្តុះបណ្តាល ដើម្បីងាយស្រួលឈានទៅរកទីផ្សារការងារ

- លើកកម្ពស់ការបណ្តុះបណ្តាលជំនាញអាជីព ជំនាញប្រកបរបរចិញ្ចឹមជីវិត និងសម្របសម្រួលឲ្យអ្នកស្វែងរកការងារទទួលបានព័ត៌មានអំពីការងារ
- បង្កើតផែនការចម្រុះសម្រាប់តាមដាននិងឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ
- លើកកម្ពស់ការពារយុវជនពីការកេងប្រវ័ញ្ចការងារនិងប្រាក់ចំណូល សុវត្ថិភាពនៅកន្លែងធ្វើការ និងការគាំពារផ្នែកសង្គមសម្រាប់គ្រួសារ
- ផ្តល់ឱកាសសមស្របដល់យុវជនសម្រាប់ការអភិវឌ្ឍផ្ទាល់ខ្លួននិងទទួលបានការយកចិត្តទុកដាក់ស្មើភាពគ្នា និងសេរីភាពក្នុងការសម្តែងអំពីកង្វល់របស់ខ្លួន ការចាត់ចែងនិងចូលរួមនៅក្នុងសេចក្តីសម្រេចចិត្តដែលមានឥទ្ធិពលដល់ជីវិតរបស់គេ
- ជំរុញការគាំទ្រយុវជនឲ្យមានស្មារតីសហគ្រិនភាពក្នុងការចាប់ផ្តើមនិងគ្រប់គ្រងអាជីវកម្មផ្ទាល់ខ្លួន និងផ្តល់សេវាគាំទ្រដល់យុវជនក្នុងមុខជំនួញឲ្យកាន់តែប្រសើរនិងមានការយល់ដឹងពីការប្រកួតប្រជែងក្នុងទីផ្សារ
- ជំរុញនិងផ្តល់ឱកាសឲ្យយុវជនធ្វើជំនួញខ្នាតតូច មធ្យម និងខ្នាតធំ និងផ្តល់ឥណទានក្នុងការចាប់ផ្តើមនិងពង្រីកមុខជំនួញ។

## *៥.៥- លើកកម្ពស់កិច្ចការពារ សុវត្ថិភាព សន្តិសុខ និងយុត្តិធម៌*

- ជំរុញកិច្ចសហប្រតិបត្តិការរវាងស្ថាប័នពាក់ព័ន្ធទាំងអស់នៅក្នុងកិច្ចការពារយុត្តិធម៌សម្រាប់យុវជន និងដោះស្រាយបញ្ហាយុវជន
- លើកកម្ពស់ការយល់ដឹងរបស់យុវជនអំពីច្បាប់ សិទ្ធិ ផលប្រយោជន៍ កាតព្វកិច្ច វចនាសម្ព័ន្ធនិងការទទួលខុសត្រូវរបស់ខ្លួន និងផ្តល់មធ្យោបាយពិគ្រោះយោបល់ឆ្លើយតបជាមួយបញ្ហាប្រឈមនានា
- បង្កើតនិងអនុវត្តកិច្ចផ្តួចផ្តើមនៅថ្នាក់ឃុំ សង្កាត់ ដើម្បីទប់ស្កាត់បទល្មើសព្រហ្មទណ្ឌដែលអាចកើតមានឡើងនៅក្នុងមជ្ឈដ្ឋានយុវជន
- ចូលរួមកែលម្អប្រព័ន្ធយុត្តិធម៌ និងវិធានការស្តារនីតិសម្បទាយុវជនដែលបានប្រព្រឹត្តបទល្មើស កែលម្អលក្ខខណ្ឌក្នុងពន្ធនាគារ ការយកចិត្តទុកដាក់ និងការស្តារនីតិសម្បទាយុវជនដែលជាអ្នកទោសក្នុងពន្ធនាគារ ស្វែងរក និងជំរុញឲ្យមានការប្រើប្រាស់ជម្រើសជំនួសការឃុំឃាំង
- សម្របសម្រួលទំនាក់ទំនងរបស់មាតាបិតាឬអ្នកអាណាព្យាបាលនិងសមត្ថកិច្ចក្នុងប្រព័ន្ធយុត្តិធម៌ ដើម្បីទប់ស្កាត់អំពើហិង្សា បទល្មើសព្រហ្មទណ្ឌ និងការប្រឈមនឹងគ្រោះថ្នាក់របស់យុវជន។

## ៩.៦- បង្កើនការចូលរួមរបស់យុវជន

- បង្កលក្ខណៈងាយស្រួលឲ្យយុវជនចូលរួមបានពេញលេញក្នុងសហគមន៍ មូលដ្ឋាន និងស្ថាប័ននានា
- ជំរុញយន្តការជាផ្លូវការឲ្យយុវជនចូលរួមប្រកបដោយប្រសិទ្ធភាពជាមួយសង្គមស៊ីវិល
- ជំរុញឲ្យមានតំណាងយុវជននៅក្នុងគណៈកម្មការឬក្រុមប្រឹក្សាថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងតំបន់ និងធានាការធ្វើសមាហរណកម្មរបស់ពួកគេទៅក្នុងដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ
- ទាក់ទាញការគាំទ្រនិងការយកចិត្តទុកដាក់ពីអ្នកតាក់តែងគោលនយោបាយ អ្នករៀបចំកម្មវិធី អ្នកផ្តល់សេវានានា និងអ្នកដឹកនាំឲ្យទទួលស្គាល់សមត្ថភាពនិងគោរពសិទ្ធិរបស់យុវជន ក្នុងការចូលរួមដោយបញ្ចេញរាល់គំនិតផ្តួចផ្តើមដើម្បីអភិវឌ្ឍសហគមន៍ និងប្រទេសជាតិ
- រៀបចំកម្មវិធីឲ្យយុវជនចេះប្រមូល ពិភាក្សា វិភាគ ចែកចាយព័ត៌មាន និងមានសមត្ថភាពផលិតព័ត៌មានដែលមានលក្ខណៈសមស្របចំពោះយុវជន
- ជំរុញការចូលរួម ការសម្តែងមតិ និងការសម្រេចចិត្តរបស់យុវជននៅក្នុងវិស័យអប់រំ
- ទាក់ទាញការគាំទ្រឲ្យមានសំឡេងយុវជននៅក្នុងដំណើរការរៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្តនានាដែលជាផលប្រយោជន៍របស់យុវជន។

## ៩.៧- លើកកម្ពស់ការសម្រាក ការកម្សាន្ត និងកីឡា

- អភិវឌ្ឍនិងជំរុញឲ្យមានហេដ្ឋារចនាសម្ព័ន្ធកីឡា ពហុកីឡដ្ឋាន និងលើកស្ទួយការចូលរួមរបស់យុវជនក្នុងការបណ្តុះបណ្តាល និងកីឡាសម្រាប់សុខភាពរាងកាយនិងបញ្ញា និងដើម្បីឈានទៅពង្រឹងការប្រកួតកីឡាជាលក្ខណៈជាតិនិងអន្តរជាតិ
- លើកកម្ពស់ការយល់ដឹងពីតម្លៃកីឡា ការឧបត្ថម្ភគាំទ្ររបស់ឪពុកម្តាយ សហគមន៍ សាលារៀន ក្លឹប សហព័ន្ធកីឡា សប្បុរសជន អ្នកនយោបាយ និងការចូលរួមរបស់យុវជនក្នុងសកម្មភាពអប់រំកាយ ការលេង និងការប្រកួតកីឡា ដើម្បីអភិវឌ្ឍសកម្មភាពកីឡាគ្រប់ប្រភេទ
- លើកកម្ពស់ការចូលរួមកម្សាន្តសប្បាយជាបុគ្គល ជាក្រុម ជាក្លឹប ដែលមានលក្ខណៈថ្លៃថ្នូរ និងសម្បូរបែប (មានលក្ខណៈមិត្តភាពនិងការផ្លាស់ប្តូរវប្បធម៌)។

### ៩.៨- លើកកម្ពស់សិល្បៈនិងវប្បធម៌

- លើកកម្ពស់ការគោរពតម្លៃនៃចំណេះដឹងនិងការយល់ដឹងអំពីប្រពៃណីជាតិ ប្រវត្តិសាស្ត្រ ការគោរពសាសនា និងការថែរក្សាបេតិកភណ្ឌវប្បធម៌ជាតិ
- លើកកម្ពស់និងគាំទ្រដល់ការផ្តួចផ្តើមថ្មីៗខាងផ្នែកភ្លេង មហោស្រពតន្ត្រី ស្ថាបត្យកម្ម ភាពយន្ត អក្សរសាស្ត្រ និងទម្រង់ផ្សេងៗទៀតខាងសិល្បៈ
- លើកកម្ពស់ការអប់រំ ដោយផ្អែកលើគោលការណ៍ជាមូលដ្ឋាននៃសិល្បៈនិងវប្បធម៌ ការចូលរួមរបស់យុវជននៅក្នុងសកម្មភាពវប្បធម៌សហគមន៍និងសមិទ្ធផលខាងសិល្បៈ
- លើកកម្ពស់ឲ្យមានវិភាគទាន ការទទួលខុសត្រូវរួមក្នុងចំណោមស្ថាប័នសិល្បៈនិងវប្បធម៌ ការកៀរគរធនធានសម្រាប់ការចាត់ចែងបណ្តុះបណ្តាលយុវអ្នកនិពន្ធនិងយុវសិល្បករ និងជំរុញផលិតផលដែលមានភាពច្នៃប្រឌិត។

### ៩.៩- លើកកម្ពស់ការយល់ដឹងពីបរិស្ថាន កសិកម្ម ទេសចរណ៍ និងធុរកិច្ច

- លើកកម្ពស់ការយល់ដឹងរបស់យុវជនស្តីពីបរិស្ថាន ការថែរក្សា និងការយកចិត្តទុកដាក់ចំពោះបរិស្ថាន
- លើកកម្ពស់ការយល់ដឹងរបស់យុវជនរវាងការអភិវឌ្ឍនិងការថែរក្សាបរិស្ថានប្រកបដោយចីរភាព
- បង្កើនការផ្សព្វផ្សាយព័ត៌មានអំពីបរិស្ថាន កសិកម្ម និងទេសចរណ៍ តាមរយៈកម្មវិធីសិក្សានិងប្រព័ន្ធផ្សព្វផ្សាយ ដែលផ្តោតលើសកម្មភាពរបស់បុគ្គលនិងសមូហភាព
- លើកកម្ពស់ឲ្យមានសហប្រតិបត្តិការរវាងយុវជននិងគ្រឹះស្ថានជំនាញ ដើម្បីកែលម្អសមត្ថភាពរបស់យុវជនលើកិច្ចការពារនិងថែរក្សាបរិស្ថាន
- ជំរុញកិច្ចការពារបរិស្ថានធម្មជាតិនិងវប្បធម៌នៅគ្រប់ទីកន្លែង ជាពិសេសតំបន់ប្រាសាទនិងតំបន់ឆ្នេរ
- ចូលរួមចងក្រងឯកសារដែលពាក់ព័ន្ធនឹងវិស័យទេសចរណ៍ប្រកបដោយនិរន្តរភាពនិងការទទួលខុសត្រូវ
- លើកកម្ពស់ការយល់ដឹងរបស់យុវជនអំពីធុរកិច្ច និងវិស័យផ្សេងៗទៀត។

### ៩.១០- បង្កើនការងារស្ម័គ្រចិត្ត

- បង្កើនការយល់ដឹងអំពីសារៈសំខាន់និងអត្ថប្រយោជន៍នៃការងារស្ម័គ្រចិត្តដល់យុវជន និងអភិវឌ្ឍបណ្តាញស្ម័គ្រចិត្តពីថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

- ជំរុញស្មារតីនិងចលនាស្ម័គ្រចិត្ត និងបញ្ជ្រាបទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ និងសកម្មភាពមនុស្សធម៌
- ជំរុញការទទួលស្គាល់ជាផ្លូវការ ឲ្យតម្លៃខ្ពស់ និងផ្តល់រង្វាន់លើកទឹកចិត្តចំពោះយុវជនដែលបានបំពេញការងារស្ម័គ្រចិត្ត
- គាំទ្រវាល់គំនិតផ្តួចផ្តើមរបស់អ្នកស្ម័គ្រចិត្តមូលដ្ឋាន អង្គការដែលពាក់ព័ន្ធនឹងការងារស្ម័គ្រចិត្ត និងគម្រោងរបស់ក្រុមយុវជនស្ម័គ្រចិត្ត
- បង្កើតយន្តការសម្របសម្រួលនិងបង្កើនកិច្ចសហប្រតិបត្តិការឲ្យមានប្រសិទ្ធភាពរវាងរដ្ឋាភិបាល អង្គការជាតិ អន្តរជាតិ និងវិស័យឯកជន ជួយយុវជនស្ម័គ្រចិត្ត។

## ៥.១១- *លើកកម្ពស់សមភាពយេនឌ័រ*

- លើកកម្ពស់និងអនុវត្តច្បាប់ គោលនយោបាយនិងក្របខ័ណ្ឌច្បាប់ដែលលើកកម្ពស់សមភាពយេនឌ័រនៅក្នុងគ្រប់ទិដ្ឋភាពនៃការរស់នៅ
- លើកទឹកចិត្តដល់សាធារណជន វិស័យឯកជន និងសង្គមស៊ីវិល ឲ្យយកចិត្តទុកដាក់ទៅលើបញ្ហាវិសមភាពយេនឌ័រនិងដោះស្រាយនូវបញ្ហាទាំងនោះ
- លើកកម្ពស់តួនាទីដឹកនាំនិងសិទ្ធិក្នុងការធ្វើសេចក្តីសម្រេចដល់យុវតី នៅក្នុងគ្រួសារ សហគមន៍ និងសង្គម
- បញ្ជ្រាបយេនឌ័រនិងការវិភាគយ៉ាងលម្អិតអំពីបញ្ហាវិសមភាពយេនឌ័រនៅក្នុងគ្រប់ផែនការសកម្មភាពទាំងអស់នៃគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជន និងបង្កើនចំណេះដឹងអំពីការងារនេះក្នុងចំណោមយុវជន ជាពិសេសយុវតី តាមរយៈកម្មវិធីអប់រំ និងកម្មវិធីបណ្តុះបណ្តាលនានា
- លើកកម្ពស់ការយល់ដឹងអំពីយេនឌ័រនៅក្នុងស្រទាប់យុវជន ដើម្បីជាមូលដ្ឋានដ៏រឹងមាំនៃការគោរពសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា និងជាដៃគូដ៏មានប្រសិទ្ធភាពរវាងបុរស និងស្ត្រីក្នុងដំណើរការអភិវឌ្ឍប្រទេសជាតិប្រកបដោយសមភាព សមធម៌ក្នុងការទទួលបានផលប្រយោជន៍។

## ៥.១២- *ទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀននិងស្ដារយុវនីតិសម្បទា*

- រៀបចំយន្តការអនុវត្តវិធានការការពារនិងបង្ការទប់ស្កាត់យុវជនឲ្យផុតពីការពាក់ព័ន្ធនឹងការដាំដុះ ការផលិត ការជួញដូរ ការចរាចរ ការរក្សាទុក ការចែកចាយនិងការប្រើប្រាស់គ្រឿងញៀនគ្រប់ប្រភេទ

- រៀបចំយន្តការមិត្តអប់រំមិត្ត ដើម្បីលើកកម្ពស់ការយល់ដឹងពីគ្រោះថ្នាក់ និងផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀន
- ជំរុញកិច្ចសហការរវាងក្រសួង ស្ថាប័នសាធារណៈ និងវិស័យឯកជន ដោយបង្កើត និងពង្រីកកម្មវិធីអប់រំ ការពារ បង្ការ ទប់ស្កាត់យុវជនឲ្យរួចផុតពីការពាក់ព័ន្ធនឹងបញ្ហាគ្រឿងញៀនគ្រប់ប្រភេទ
- បង្កើននិងអភិវឌ្ឍមជ្ឈមណ្ឌលស្តារនីតិសម្បទា ដើម្បីព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលជំនាញផ្សេងៗដល់យុវជនរងគ្រោះ និងធ្វើសមាហរណកម្មចូលក្នុងសង្គមវិញ។

## ៦-ផែនការសកម្មភាព

ដើម្បីសម្រេចយុទ្ធសាស្ត្រខាងលើ ត្រូវយកចិត្តទុកដាក់លើសកម្មភាពមួយចំនួនដូចខាងក្រោម៖

*៦.១- ការបង្កើតយន្តការ*

- បង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន ដែលជាយន្តការសម្របសម្រួល តាមដាន វាយតម្លៃ និងជួយរាជរដ្ឋាភិបាលអំពីដំណើរការអភិវឌ្ឍយុវជន។ ក្រុមប្រឹក្សានេះ មានអគ្គលេខាធិការដ្ឋាននិងអនុគណៈកម្មការជាតិជំនាញមួយចំនួនដើម្បីអនុវត្ត និងទ្រទ្រង់សកម្មភាព
- បង្កើតក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន ដែលជាយន្តការតាមដានវាយតម្លៃ អំពីការអភិវឌ្ឍយុវជន និងរាយការណ៍ជូនក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន
- បង្កើតក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនរាជធានី ខេត្ត ដែលជាបណ្តាញរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន និងជាយន្តការថ្នាក់ក្រោមជាតិសម្រាប់សម្របសម្រួល និងជួយគណៈអភិបាលរាជធានី ខេត្ត អំពីដំណើរការអភិវឌ្ឍយុវជននៅរាជធានី ខេត្ត
- បង្កើតក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រុង ស្រុក ខណ្ឌ ដែលជាយន្តការសម្របសម្រួលដំណើរការអភិវឌ្ឍយុវជននៅថ្នាក់ក្រុង ស្រុក ខណ្ឌ
- បង្កើតក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនឃុំ សង្កាត់ដែលជាយន្តការសម្របសម្រួលដំណើរការអភិវឌ្ឍយុវជននៅមូលដ្ឋាន
- ពង្រឹងយន្តការដែលមានស្រាប់ដើម្បីគាំទ្រការអភិវឌ្ឍយុវជន។

### ៦.២- *ការបង្កើតក្រុមខណ្ឌតិយុត្ត*

- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជនស្ថិតក្រោមការដឹកនាំរបស់នាយករដ្ឋមន្ត្រី។ សមាសភាពរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជនត្រូវតែងតាំងដោយព្រះរាជក្រឹត្យ
- ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជនត្រូវកំណត់ដោយអនុក្រឹត្យ
- ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន អនុគណៈកម្មការជាតិជំនាញនានា និងក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនរាជធានី ខេត្ត ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន
- ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនរាជធានី ខេត្ត
- ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនឃុំ សង្កាត់ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រុង ស្រុក ខណ្ឌ។

### ៦.៣- *ការគាំទ្រហិរញ្ញវត្ថុ*

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជនប្រើប្រាស់ថវិកាដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា និងដែលបានមកពីប្រភពផ្សេងៗទៀតសម្រាប់ដំណើរការការងាររបស់ខ្លួន។

### ៦.៤- *ការបណ្តុះបណ្តាលធនធានមនុស្ស*

ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ត្រូវយកចិត្តទុកដាក់បណ្តុះបណ្តាលភាពជាអ្នកដឹកនាំ ការរៀបចំផែនការ ការវិភាគទិន្នន័យជំនាញបច្ចេកទេស ដែលពាក់ព័ន្ធនឹងការងារយុវជន។

### ៦.៥- *ដំណើរការអនុវត្តគម្រោង*

រៀបចំផែនការអភិវឌ្ឍយុវជនរយៈពេលមធ្យម ដោយមានការពិគ្រោះយោបល់ពីគ្រប់ដៃគូពាក់ព័ន្ធ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយ។ ផែនការនេះត្រូវបង្ហាញពីចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការអភិវឌ្ឍយុវជនសម្រាប់រយៈពេលខាងមុខ និងត្រូវ

ឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ។ ផែនការនេះ ក៏ត្រូវអនុវត្តនៅក្នុងក្របខ័ណ្ឌកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលផងដែរ។

## ៧-ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ

ដើម្បីឲ្យគោលនយោបាយនេះមានវិសាលភាពអនុវត្តស្របតាមបរិបទកម្ពុជា ចាំបាច់ត្រូវមានប្រព័ន្ធតាមដានត្រួតពិនិត្យ វាយតម្លៃ ការពិនិត្យឡើងវិញ និងសំណើកែលម្អការអនុវត្ត ដោយផ្តោតលើ៖

- ចំណុចដៅនិងយុទ្ធសាស្ត្រនៃគោលនយោបាយជាតិដើម្បីអភិវឌ្ឍយុវជនកម្ពុជា
- សូចនាករនៃផែនការជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា
- លទ្ធផលដែលទទួលបានធៀបទៅនឹងចំណុចដៅ
- ការចូលរួមរបស់យុវជនក្នុងការកសាងប្រទេសជាតិ
- ផលប្រយោជន៍ដែលយុវជនទទួលបានពីការអនុវត្តគោលនយោបាយ។

## ៨-សេចក្តីសន្និដ្ឋាន

គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ទទួលស្គាល់ពីបំណងប្រាថ្នា តម្រូវការ និងលក្ខខណ្ឌរបស់យុវជន ដោយបានបញ្ជាក់ច្បាស់អំពីចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្ត្រមួយចំនួន ដើម្បីប្រមូលផ្តុំកម្លាំងយុវជនគ្រប់មជ្ឈដ្ឋាន និងកៀរគរធនធាន សំដៅអភិវឌ្ឍយុវជនឲ្យក្លាយទៅជាពលរដ្ឋមានកាយសម្បទា ចំណេះដឹង ចំណេះធ្វើ មានគំនិតផ្តួចផ្តើម គំនិតបង្កើតថ្មី និងស្មារតីសហគ្រិនភាព ដែលជាកត្តាកំណត់សក្តានុពលសេដ្ឋកិច្ចសង្គមជាតិទាំងមូល។

រាជរដ្ឋាភិបាលសង្ឃឹមនិងជឿជាក់ថា ក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល សហគមន៍ គ្រួសារ បុគ្គល នឹងចូលរួមចំណែកជំរុញ ផ្សព្វផ្សាយ អនុវត្ត និងគាំទ្រគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជាឲ្យបានជោគជ័យ។